# ធ្វើជាសាក្សីនៃការការពារ និងកំណើតថ្មីនៃបេតិកភណ្ឌវប្បធម៌

# 见证文化遗产的守护与新生

本刊记者 李吒 / 文

世界文化遗产红河哈尼梯田遗产区的重点村落阿者科村带给谢莫尼勒许多惊喜和思考。这里依托自然风光和人文景观发展旅游业，既保护了生态环境和当地民族文化，又实现了村庄经济的可持续发展。谢莫尼勒认为，柬埔寨北部山区拥有秀美的自然风光和多样的民族文化，在乡村振兴和乡村旅游发展方面，阿者科村的发展模式值得研究和借鉴。



ផ្ទះផ្សិតក្នុងភូមិអាជឺខឺ
阿者科村的蘑菇房 李吒 图

លោកបណ្ឌិត ជា មុនីឫទ្ធិ ដែលស្លៀកសម្លៀកបំពាក់ប្រពៃណីខ្មែរ ដើរតាមផ្លូវបត់បែនតូចចូលក្នុងភូមិអាជឺខឺ ស្រុកយាន់យ៉ាង មណ្ឌលស្វយ័តជនជាតិហានី និងជនជាតិយី ហុងហឺ ខេត្តយូណាននៃប្រទេសចិន ដែលជាភូមិប្រពៃណីជាតិនៃប្រទេសចិន និងជាភូមិសំខាន់មួយក្នុងតំបន់ដីស្រែកាំជណ្ដើរ ហានី ហុងហឺ ដែលជាបេតិកភណ្ឌវប្បធម៌ពិភពលោក។

ដើរចូលផ្ទះសំណាក់មួយកន្លែងដែលមានឈ្មោះថា "យាន់សឺ អាជឺខឺ" នារីស្រស់ស្អាតស្លៀកសម្លៀកបំពាក់ប្រពៃណីជនជាតិហានី បានដើរមកជំរាបសួរយ៉ាងរួសរាយរាក់ទាក់ជាមួយលោកបណ្ឌិត ជា មុនីឫទ្ធិ ថា "ខ្ញុំឈ្មោះ ចាំង ភីង លោកអាចហៅខ្ញុំ សៀវហួ បាន។ សូមអញ្ជើញ ខ្ញុំសូមនាំលោកមកមើលទេសភាពដីស្រែកាំជណ្ដើរនៅទីនេះ ព្រមទាំងភ្លក់រសជាតិតែភូអឺរបស់យើង"។ សៀវហួ គឺជាអ្នកគ្រប់គ្រងផ្ទះសំណាក់នេះ។

សូមស្កេន QR កូដដើម្បីទស្សនាវីដេអូ
扫描二维码，轻松看视频

ឈរនៅរានហាលក្នុងផ្ទះសំណាក់ ក្រសែភ្នែករបស់លោកបណ្ឌិត ជា មុនីឫទ្ធិ សម្លឹងមើលដីស្រែកាំជណ្ដើរម្ដងហើយម្ដងទៀត លោកបណ្ឌិតបញ្ជាក់ថា ពីមុនលោកតែងតែគិតថា ដីស្រែកាំជណ្ដើរដ៏ស្រស់ស្អាតបែបនេះមានតែឃើញនៅក្នុងគំនូរ ប៉ុន្តែ នៅពេលដែលពិតជាឈរនៅក្បែរដីស្រែកាំជណ្ដើរតាមថ្នាក់ៗបែបនេះ មើលឃើញអព្ភូតហេតុនេះដែលរួមគ្នាបង្កើតដោយមនុស្ស និងធម្មជាតិដោយផ្ទាល់ភ្នែក ទើបលោកបណ្ឌិតបានយល់ច្បាស់ពីភាពស្រស់ស្អាតពិតប្រាកដដែលដក់ជាប់ក្នុងបេះដូងបែបនេះ។ សៀវហួ ឆុងតែបណ្ដើរ និយាយរឿងនៅទីនេះប្រាប់លោក-បណ្ឌិត ជា មុនីឫទ្ធិ បណ្ដើរ។

សៀវហួ និយាយថា ភូមិអាជឺខឺមានជនជាតិហានីរស់-នៅដ៏ឧស្សាហ៍ព្យាយាម។ "យើងបានប្រកបរបរចិញ្ចឹមជីវិតដោយធ្វើស្រែចំការជាច្រើនជំនាន់ បានពឹងផ្អែកលើធម្មជាតិ និងប្រាជ្ញារបស់បុព្វបុរសរបស់យើង បង្កើតបានវាលស្រែដ៏ស្រស់ស្អាតនេះ។ នៅទីនេះ ព្រៃឈើអភិរក្សប្រភពទឹកប្រភពទឹកផ្ដល់ជីជាតិដល់ផ្ទៃដីស្រែកាំជណ្ដើរ ហើយដីស្រែ-កាំជណ្ដើរចិញ្ចឹមបីបាច់ពួកយើង។ ឥឡូវនេះ ការអភិវឌ្ឍវិស័យទេសចរណ៍បានធ្វើឱ្យជីវិត និងស្មារតីរបស់យើងកាន់តែមានភាពសម្បូរបែប"។ អ្នកភូមិនៅទីនេះនៅតែពឹងផ្អែកលើមធ្យោបាយដឹកជញ្ជូនបែបប្រពៃណីដូចជាកម្លាំងមនុស្ស និងសេះ ហើយការងារប្រចាំថ្ងៃដូចជាការដឹកជញ្ជូនសម្ភារៈនៅក្នុងផ្ទះសំណាក់ គឺមានភាពស្រដៀងគ្នាដែរ។ ពួកគេសង្ឃឹមថានឹងខិតខំការពារបរិស្ថានអេកូ-ឡូស៊ីក្នុងតំបន់ឱ្យបានល្អប្រសើរ ព្រមទាំងរក្សានូវរបៀបការរស់នៅបែបប្រពៃណី។

សៀវហួ បានណែនាំបន្ថែមថា ផ្ទះសំណាក់នេះ



អ្នកភូមិអាជឺខឺ
阿者科村村民 李吒 图

ត្រូវបានកែច្នៃឡើងវិញពីលំនៅដ្ឋានបុរាណចំនួន ៥ ខ្នង គោលបំណងនៃការបើកផ្ទះសំណាក់ មិនត្រឹមតែរកប្រាក់ចំណេញប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងនេះទៅទៀតគឺដើម្បីផ្សព្វផ្សាយពីភាពទាក់ទាញនៃវប្បធម៌ភូមិអាជឺខឺ និងជួយអ្នកភូមិការពាររតនសម្បត្តិវប្បធម៌ជនជាតិភាគតិចដ៏មានតម្លៃ និងផ្ទះប្រពៃណីបុរាណរបស់ពួកគេតាមរយៈការអភិវឌ្ឍទេសចរណ៍។

ភូមិអាជឺខឺអភិវឌ្ឍទេសចរណ៍ដោយពឹងផ្អែកលើទេសភាពធម្មជាតិ និងវប្បធម៌ មិនត្រឹមតែការពារបរិស្ថានអេកូឡូស៊ី និងវប្បធម៌ជនជាតិភាគតិចក្នុងតំបន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចភូមិដោយចីរភាពផងដែរ។ ទាំងនេះបាននាំមកនូវការភ្ញាក់ផ្អើល និងបំផុសគំនិតជាច្រើនដល់លោកបណ្ឌិត ជា មុនីឫទ្ធិ។ លោកបានបញ្ជាក់ថា "តំបន់ភ្នំនៅភាគខាងជើងនៃប្រទេសកម្ពុជាមានទេសភាពធម្មជាតិដ៏ឆើតឆាយ និងវប្បធម៌ជនជាតិភាគតិចដ៏ចម្រុះពណ៌ បើនិយាយអំពីការស្តារតំបន់ជនបទ និងការអភិវឌ្ឍទេសចរណ៍តាមទីជនបទ រូបមន្តអភិវឌ្ឍន៍របស់ភូមិអាជឺខឺគឺគួរឱ្យយើងធ្វើការស្រាវ-ជ្រាវ និងសិក្សារៀនសូត្រ"៕